**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣✵៤

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៧៩០ ស.អ.យ.

**លិខិតចូល**
ថ្ងៃទី21 ខែ07 ឆ្នាំ2006

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពីការបង្កើតមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់របស់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញព្រះរាជក្រមលេខ / នស.រកម / ០១៩៧ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន.
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.
- បានឃើញប្រកាសលេខ ៣៧៥ សអយ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង.
- ពិនិត្យតាមការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១ :** បង្កើតមណ្ឌលមណ្ឌល **ជីវិតថ្មីភ្នំបាក់** អោយស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបន្ទាយមានជ័យ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឈ្មោះថា **ជីវិតថ្មីភ្នំបាក់** ខេត្តបន្ទាយមានជ័យ ។

**ប្រការ២ :** ប្រធានមជ្ឈមណ្ឌលជីវិតថ្មីផ្ទំបាក់របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយ-មានជ័យ មានឋានៈស្មើអនុប្រធានការិយាល័យនៃមន្ទីរខេត្ត-ក្រុង និងមានអនុប្រធានមួយចំនួនជាជំនួយការ ដែលមានឋានៈស្មើអនុប្រធានការិយាល័យស្រុក-ខណ្ឌ ។

**ប្រការ៣ :** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គ-

នាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-បន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សៀ ផាន់**
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សាលាខេត្តបន្ទាយមានជ័យ " ដើម្បីជូនជ្រាប "
- ដូចប្រការ៣ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**អ៊ិត សំហេង**

**អង្គការលេខមជ្ឈមណ្ឌលជីវិតថ្មីគាំពារនៅថ្នាក់ខេត្ត**
**ដែលស្ថិតក្រោមឱវាទរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**ខេត្តបន្ទាយមានជ័យ**

